គេហទំព័រសិក្សាភាសាជប៉ុនសម្រាប់ "អ្នករស់នៅដែលជាជនបរទេស"

# តភ្ជាប់ និង អភិវឌ្ឍ ការរស់នៅតាមរយៈភាសាជប៉ុន




គេហទំព័រសិក្សាភាសាជប៉ុនសម្រាប់ជនបរទេសកំពុងរស់នៅក្នុងប្រទេសជប៉ុន
ដែលពួកគេអាចសិក្សាភាសាជប៉ុនដើម្បីប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃបាន។

សម្រាប់គេហទំព័រ
ដំណើរការលើ PC SP

tsunagarujp.bunka.go.jp/?lang_id=KH

文化庁
Agency for Cultural Affairs, Government of Japan

# របៀបប្រើ

## ចំណុច ១ ដំណើរការជាមួយពហុភាសា

ដំណើរការជាមួយនឹង១០ភាសា ព្រមទាំងអក្សររ៉ូម៉ាជិ។

ភាសាជប៉ុន ភាសាអង់គ្លេស ភាសាចិន(អក្សរសាមញ្ញ) ភាសាអេស្ប៉ាញ ភាសាព័រទុយហ្គាល់ ភាសាវៀតណាម ភាសាឥណ្ឌូនេស៊ី ភាសាហ្វីលីពីន ភាសានេប៉ាល់ ភាសាខ្មែរ



## ចំណុច ២ ជំនាញក្នុងជីវភាពរស់នៅ

ជំនាញក្នុងការរៀនភាសាជប៉ុនដែលត្រូវបានប្រើក្នុងជីវិតប្រចាំថ្ងៃរបស់ជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន។





**ជ្រើសរើសភាសា**

**ប្រធានបទ និង គោលដៅ**

បង្ហាញពីប្រធានបទនិងគោលដៅសម្រាប់ឈុតឆាកនីមួយៗ។

**ពាក្យគន្លឹះ**

បង្ហាញពីពាក្យគន្លឹះដែលអាចរៀនបាននៅក្នុងគេហទំព័រនេះ។

**វីដេអូ**

មានបង្ហាញវីដេអូយោងទៅតាមប្រធានបទ។

**ចំណងជើងរង**

ការសន្ទនានឹងត្រូវបានបង្ហាញយោងទៅតាមវីដេអូ។ អ្នកអាចជ្រើសរើសចំណងជើងរងពីភាសាជប៉ុន រ៉ូម៉ាជិ និងភាសាបរទេស។

**អត្ថបទ**

អាចមើលគ្រប់ការសន្ទនាទាំងអស់ដែលមាននៅក្នុងវីដេអូ។

**ចងចាំឃ្លានេះ**

អ្នកអាចរៀនដោយកត់ចំណាំឃ្លាសំខាន់ៗដែលបង្ហាញនៅក្នុងវីដេអូ។

**ចងចាំពាក្យនេះ**

អ្នកអាចរៀនពីអត្ថន័យនៃពាក្យសំខាន់ៗដែលបង្ហាញនៅក្នុងវីដេអូ។

**ពាក្យដែលមានប្រយោជន៍**

អាចមើលបញ្ជីពាក្យមានប្រយោជន៍ដែលទាក់ទងនឹងពាក្យលើកឡើងនៅក្នុងឈុតឆាកនីមួយៗ។




**ព័ត៌មានដែលមានប្រយោជន៍**

អាចទទួលបានព័ត៌មានល្អៗដែលគួរដឹងទុកជាមុនទាក់ទងនឹងឈុតឆាកលើកឡើងនៅក្នុងវីដេអូ។

## ចំណុច ៣ រៀនដោយផ្តោតលើវីដេអូជាគោល

មានឯកសារបង្រៀនជាច្រើនដែលងាយស្រួលយល់ទាំងការមើលនិងការស្តាប់ ដូចជាវីដេអូដែលយកគម្រូតាមជីវភាពរស់នៅជាក់ស្តែង និងវីដេអូដែលពន្យល់ពីទម្រង់ប្រយោគ។



## ចំណុច ៤ បង្ហាញពីចំណេះដឹងគ្រឹះរបស់ភាសាជប៉ុន

មានបង្ហាញព័ត៌មានល្អៗជាច្រើនដែលគួរដឹងទុកជាមុន មុននឹងចាប់ផ្តើមរៀនភាសាជប៉ុន ដូចជាលក្ខណៈពិសេសរបស់ភាសាជប៉ុន និងការបំបែកកិរិយាសព្ទជាដើម។






## អាចរៀនតាមរយៈឈុតឆាកបែបនេះ!

### ▼ ទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ



Sumimasen. Gyuunyuu wa doko desu ka.
សុំអភ័យទោស។ តើទឹកដោះគោនៅឯណា?

Gyuunyuu desu ne. Kochira desu.
ទឹកដោះគោ មែនទេ? គឺនៅទីនេះ។

Arigatoo gozaimasu.
អរគុណ។

Iie, doo itashimashite.
មិនបាច់គួរសមទេ។

### ▼ ទៅមន្ទីរពេទ្យ



Nenza desu.
គឺគ្រេចកជើង។

Jaa, ofuro ni haittemo ii desu ka.
អញ្ចឹង ខ្ញុំអាចត្រាំក្នុងអាងងូតទឹកបានទេ?

Aa, ofuro wa, ni-san-nichi, hairanaide kudasai.
អា ហាមចូលក្នុងរយៈពេល២ទៅ៣ថ្ងៃ។

Wakarimashita.
យល់ហើយ។

# យើងអាចប្រើគេហទំព័ររបៀបនេះបាន

អាចប្រើប្រាស់គេហទំព័រធ្វើជាឯកសាររៀនសូត្រសម្រាប់អ្នកដែលមានបំណងចង់សិក្សាភាសាជប៉ុនដោយខ្លួនឯង ហើយក៏អាចប្រើប្រាស់នៅក្នុងថ្នាក់ភាសាជប៉ុនបានផងដែរ។

## មតិរបស់អ្នកដែលបានប្រើប្រាស់ជាក់ស្តែង

### សមាគមទំនាក់ទំនងអន្តរជាតិក្រុងណាកាណុតុ (ខេត្តអ៊ិស៊ិការ៉ា)

**PHAN THI HUYNH LIEN** វៀតណាម

ប្រធានបទដែលខ្ញុំចូលចិត្តគឺ “ទៅមន្ទីរពេទ្យ”។ មានមនុស្សមួយចំនួនមិនចេះភាសាជប៉ុនទេហើយសុខចិត្តស៊ូទ្រាំនឹងជំងឺ ដូច្នេះខ្ញុំគិតថាគេហទំព័រនេះពិតជាល្អដោយសារយើងអាចរៀនពីអ្វីដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។ វាក៏ល្អផងដែរដោយសារយើងអាចពិនិត្យមើលពាក្យដែលស្តាប់មិនបានដោយមើលចំណងជើងរង។





### នាយកដ្ឋានជីវភាពប្រជាពលរដ្ឋ ផ្នែកអភិវឌ្ឍន៍ទីក្រុង ក្រុងអ៊ិម៉ារី (ខេត្តស៊ីហ្គា)

**Zhang Jie** ចិន

តាមរយៈគេហទំព័រនេះ យើងអាចរៀនបានយ៉ាងងាយស្រួលនូវការសន្ទនាដើម្បីឲ្យទម្លាប់ក្នុងជីវភាពនៅប្រទេសជប៉ុន។ រៀន“ភាសាជប៉ុនសំខាន់ៗសម្រាប់និយាយ” ដោយជ្រើសរើសទៅតាមកម្រិតរបស់អ្នកហើយរីករាយជាមួយនឹងជីវិតនៅប្រទេសជប៉ុនចាប់ពីពេលឥឡូវនេះទាំងអស់គ្នា។

### សមាគមទំនាក់ទំនងអន្តរជាតិ ខេត្តហ្យូហ្គុ

បុគ្គលិកអប់រំភាសាជប៉ុន **ENDO Chisa**

ខ្ញុំតែងតែសង្ឃឹមចង់បានឯកសាររៀនបែបនេះ។ គេហទំព័រនេះមានភាពទាក់ទាញត្រង់ចំណុចដែលយើងអាចរៀនដោយខ្លួនឯងបានចំពោះអ្នកដែលមិនមានថ្នាក់រៀននៅក្បែរ។ ខ្ញុំចង់សាកល្បងប្រើប្រាស់ដោយសារវាមានវីដេអូជាច្រើន មានការបកប្រែជាភាសាបរទេស ការពន្យល់ពីទម្រង់ល្បះ ដែលអាចយកទៅប្រើនៅក្នុងសកម្មភាពថ្នាក់រៀនបានផងដែរ។






ទំនាក់ទំនង

**ទីភ្នាក់ងារវប្បធម៌ ផ្នែកភាសាជាតិ**

ទូរសព្ទ៖ ០៣ ៥២៥៣ ៤១១១ (តំណាង)

អ៊ីមែល៖ chiikinihongo@mext.go.jp


©Japanese Language Division, Agency for Cultural Affairs

202104 クメール語